# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ ០១-៣-១-១៣.សរ-៩៧

## សារាចរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**លោក ប្រធានតុលាការកំពូល និងលោកព្រះរាជអាជ្ញាអមតុលាការកំពូល**

**លោក ប្រធានសាលាឧទ្ធរណ៍ និងលោកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

**លោក ប្រធានតុលាការយោធា និងលោកព្រះរាជអាជ្ញាអមតុលាការយោធា**

សូមជ្រាប

**កម្មវត្ថុ:** អំពីការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។

**យោង:** មាតិកា ៤ ស្តីពីបទល្មើសឧក្រិដ្ឋ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-០៩-៩២ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា ការផ្តន្ទាទោសជនល្មើសដែលជាប់ចោទ ៦ ពីបទឧក្រិដ្ឋនៅមានកម្រិតទាបស្រាល ដែលជាហេតុធ្វើអោយអំពើល្មើសបែបនេះ គ្មានការថយចុះសោះ ។

ក្រសួងសូមអោយលោកយកចិត្តទុកដាក់ចាប់អារម្មណ៍ក្នុងការបង្ក្រាបបទល្មើសនេះ ឱ្យបានទទួលលទ្ធផលជាអតិបរមាដោយពិនិត្យពិចារណាអោយបានល្អិតល្អន់ និងហ្មត់ចត់ជាទីបំផុតចំពោះស្ថានសម្រាលនិងស្ថានទម្ងន់ទោសទៅលើអំពើរបស់ឧក្រិដ្ឋជនទាំងនោះអោយបានច្បាស់លាស់ និងប្រាកដប្រជាទៅតាមសកម្មភាពរបស់ឧក្រិដ្ឋជនដែលបានការប្រព្រឹត្តដើម្បីកំណត់បទល្មើស និងទោសទណ្ឌកម្មអោយបានត្រឹមត្រូវទៅតាមមាត្រា ៣១ ដល់មាត្រា ៣៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សូមលោកចាប់អារម្មណ៍អោយបានខ្ពស់ថា អង្គការតុលាការ និងអង្គការអយ្យការ ជាអង្គការបង្ក្រាបបទល្មើសដោយផ្អែកលើច្បាប់ ។ ដូច្នេះអំណើះតទៅចំពោះជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ គប្បីអស់លោកអនុវត្តឱ្យបានតឹងរឹង និងហ្មត់ចត់ជាទីបំផុតផ្អែកតាមច្បាប់ជាធរមាន ។

ក្រសួងសង្ឃឹមថា អស់លោកប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះអោយល្អប្រសើរ ដើម្បីបន្ថយអំពើល្មើសឧក្រិដ្ឋឱ្យបានថយចុះក្នុងគោលដៅជំរុញប្រទេសជាតិយើងអោយឈានទៅកាន់នីតិរដ្ឋ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**